សៀវភៅប្រតិបត្តិ

ប្រធានាធិប្បាសា

២០១៤-២០២៦

ប្រវត្តិវិទ្យា

ថ្នាក់ទី១២

ថ្នាក់វិទ្យាសាស្ត្រ និង វិទ្យាសាស្ត្រសង្គម

2026

រៀបរៀងដោយ ឈិន ចណ្ឌី

ប្រធានវិញ្ញាសាឆ្លាប់ចេញប្រឡងបាក់ឌុប

ឆ្នាំ២០១៤-២០២៦

((មិនមានអត្រាកំណែតាមវិញ្ញាសានីមួយៗទេ))

ថ្នាក់វិទ្យាសាស្ត្រសង្គម	ថ្នាក់វិទ្យាសាស្ត្រ
សម័យប្រឡង ០៤ សីហា ២០១៤(លើកទី១)	
១-ពណ៌នាអំពីទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃសាកលភាវូបនីយកម្ម។ ២-តើព្រះបាទសម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន មានតួនាទីអ្វីខ្លះក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា? ៣-តើអាស៊ានជាអ្វី? ហើយមានសារៈសំខាន់អ្វីខ្លះសម្រាប់កម្ពុជា?	១-តើពិភពលោកកំពុងជួបប្រទះនឹងបញ្ហាធំៗអ្វីខ្លះ? ២-ពណ៌នាអំពីវិនាសសកម្មនៅក្រោមរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ និងការស្ថាបនាកម្ពុជាឡើងវិញ។ ៣-ការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកមានអត្ថន័យដូចម្តេចសម្រាប់កម្ពុជា?
សម័យប្រឡង ១៣ តុលា ២០១៤(លើកទី២)	
១-តើព្រះបាទជ័យវរ្ម័នទី៧ បានធ្វើអ្វីខ្លះនៅក្នុងប្រវត្តិសាស្ត្រខ្មែរ ? ២-ពណ៌នាអំពីបញ្ហាសន្តិសុខស្បៀងដែលពិភពលោកកំពុងជួបប្រទះ។	១-តើប្រាសាទអង្គរវត្តបានសាងសង់នៅក្នុងរជ្ជកាលនៃព្រះមហាក្សត្រអង្គណា? ២-ពណ៌នាអំពីនយោបាយបង្រួបបង្រួមជាតិដែលនាំមកនូវសន្តិភាពនៅកម្ពុជា។

៣-មូលហេតុអ្វីបានជាត្រូវកាត់ទោសមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម)?	៣-ចូររៀបរាប់ពីព្រឹត្តិការណ៍សំខាន់ៗនៃប្រទេសកម្ពុជា នាសតវត្សទី២០។
សម័យប្រឡង ២៤ សីហា ២០១៥	
១-តើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តមសីហនុ កើតឡើងនៅឆ្នាំណា ? ២-តើរដ្ឋប្រហារនេះបាននាំមកអ្វីខ្លះសម្រាប់កម្ពុជា? ៣-ចូរពណ៌នាពីគោលនយោបាយឈ្នះ-ឈ្នះរបស់ សម្តេច ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា។ ៤-ចូរវិភាគពីតួនាទីព្រះពុទ្ធសាសនានៅក្នុងសង្គមកម្ពុជា។ ៥-ចូរវិភាគពីព្រះរាជាណាចក្រកម្ពុជាទី២ និងការកសាងកម្ពុជាឡើងវិញ។	១-តើកម្ពុជាទទួលបានឯករាជ្យពីបារាំងនៅឆ្នាំណា? ២-តើការទទួលឯករាជ្យនេះមានន័យយ៉ាងដូចម្តេចសម្រាប់កម្ពុជា? ៣-ចូរពណ៌នាពីមូលហេតុដែលកម្ពុជាទទួលយកអាណានិគមនិយមបារាំង។ ៤-ចូរវិភាគពីតម្លៃសន្តិភាពដែលកម្ពុជាទទួលបានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ៥-ចូរបកស្រាយពីតួនាទីនៃ«វប្បធម៌សន្ធនា»នៅក្នុងសង្គមប្រជាធិបតេយ្យ។
សម័យប្រឡង ២២ សីហា ២០១៦	
១-តើនរណាគេជាមេខ្មែរក្រហម? សូមរាប់ឱ្យបាន៣នាក់។ ២-ហេតុអ្វីបានជាកម្ពុជារងការបំផ្លិចបំផ្លាញក្នុងរបបខ្មែរក្រហម? ៣-តើអាស៊ានជាអ្វី? ហើយតើកម្ពុជាបានទទួលផលប្រយោជន៍អ្វីខ្លះពីការចូលជាសមាជិកអាស៊ាន? ៤-ចូរពណ៌នាពីការកសាងជាតិឡើងវិញក្រោយរបបខ្មែរក្រហម ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩០។	១-អ្នកប្រាជ្ញខ្មែរឈ្មោះអ្វីដែលបានរៀបចំវចនានុក្រមខ្មែរ? ២-តើអាណាព្យាបាលបារាំងពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ មានចំណុចវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះសម្រាប់កម្ពុជា? ៣-ចូរពណ៌នាសមិទ្ធផលសង្គមវាស្ត្រនិយមពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧០? ៤-ចូរពណ៌នាពីមូលហេតុដែលធ្វើឱ្យសង្គ្រាមស៊ីវិលផ្ទុះឡើងពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥។

៥-តើពិភពលោកយើងនាពេលបច្ចុប្បន្ននេះកំពុងជួបប្រទះនឹងបញ្ហាធំអ្វីៗខ្លះ?	៥-តើសង្គ្រាមពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា?
សម័យប្រឡង ២១ សីហា ២០១៧	
១-តើសមាគមអាស៊ានមានសមាជិកប៉ុន្មាន? ប្រទេសណាខ្លះ? ២-ហេតុអ្វីបានជាកម្ពុជាចាំបាច់ស្វែងរកកិច្ចការពារពីបារាំងដោយចុះសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំង? ៣-ចូរពណ៌នាពីនយោបាយអព្យាក្រឹតនៅក្នុងរបបសង្គមរាស្ត្រនិយម(១៩៥៣-១៩៧០)។ ៤-តើសង្គ្រាមនៅកម្ពុជាក្នុងឆ្នាំ១៩៧០-១៩៧៥ និងឆ្នាំ១៩៧៩-១៩៩៨ និងរបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) មានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា? ៥-មូលហេតុអ្វីបានជាគេចាត់ទុកថា សម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ជាបិតាសន្តិភាពនៅកម្ពុជា?	១-តើស្តេចខ្មែរអង្គណាដែលទាមទារបានសម្រេចឯករាជ្យពីបារាំង? ២-តើសង្គ្រាមត្រជាក់ក្នុងទសវត្សរ៍ ១៩៥០ ដល់ ១៩៦០ នាំមកអ្វីខ្លះដល់ឧបទ្វីបឥណ្ឌូចិន? ៣-ចូរពណ៌នាពីកត្តាសំខាន់ៗដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥) ដួលរលំ។ ៤-ចូរពណ៌នាពីចលនាតស៊ូដើម្បីរំដោះប្រទេសកម្ពុជា ពីរបបប្រល័យពូជសាសន៍ "កម្ពុជាប្រជាធិបតេយ្យ" (ឆ្នាំ១៩៧៥-១៩៧៩)។ ៥-ចូរពណ៌នាពីសមិទ្ធផលរបស់រាជរដ្ឋាភិបាល ១៩៩៣ ដល់ពេលបច្ចុប្បន្ន។
សម័យប្រឡង ២០ សីហា ២០១៨	
១-តើសហគមន៍អឺរ៉ុបជាអ្វី? ២-ចូរអត្ថាធិប្បាយពីចំណុចវិជ្ជមាននិងអវិជ្ជមាននៃរបបអាណាព្យាបាលបារាំងនៅកម្ពុជា។ ៣-ចូរពណ៌នាពីកម្ពុជាសម័យសង្គមរាស្ត្រនិយម(១៩៥៣-១៩៧០)។	១-តើអ្នកនយោបាយខ្មែរណាដែលបានបញ្ចប់សង្គ្រាមក្នុងស្រុកនៅឆ្នាំ១៩៩៨? ២-តើអាណាព្យាបាលបារាំងនាំមកអ្វីខ្លះដល់កម្ពុជា?

៤-មូលហេតុអ្វីបានជារបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ (១៩៧០-១៩៧៥) សម្លាប់មនុស្សហើយតើវាមានផលវិបាកអ្វីខ្លះដល់កម្ពុជា? ៥-ចូរពណ៌នាពីដំណើរការកសាងកម្ពុជាឡើងវិញចាប់ពីឆ្នាំ១៩៩៨ មកដល់ពេលបច្ចុប្បន្ន។	៣-ចូរពណ៌នាពីកត្តាសំខាន់ៗដែលធ្វើឱ្យរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥-១៩៧៩) ដួលរលំ។ ៤-ចូរពណ៌នាពីតួនាទីរបស់សហគមន៍អាស៊ានៅអាស៊ីអាគ្នេយ៍។ ៥-តើសន្តិភាពដែលសម្រេចបានចាប់តាំងពីឆ្នាំ១៩៩៨ បាននាំមកអ្វីខ្លះដល់កម្ពុជា?
សម័យប្រឡង ១៩ សីហា ២០១៩	
១-អ្វីទៅជាគោលនយោបាយអព្យាក្រឹត? ចូរអ្នកពណ៌នា។ ២-ហេតុអ្វីបានជារបបសាធារណរដ្ឋខ្មែរឆ្នាំ១៩៧០-១៩៧៥ដួលរលំ? ៣-ហេតុអ្វីបានជាតុលាការយកមេដឹកនាំកំពូលរបស់ខ្មែរក្រហមដែលកាន់អំណាចនៅឆ្នាំ១៩៧៥-១៩៧៩ ទៅកាត់ទោស? ៤-ចូរអ្នកពិពណ៌នាពីការខិតខំចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិនៅកម្ពុជា។ ៥-ចូរអ្នកពិពណ៌នាពីការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជាពីឆ្នាំ១៩៩៣ ដល់សព្វថ្ងៃ។	១-ចូររៀបរាប់ពីឈ្មោះមេដឹកនាំខ្មែរក្រហមសំខាន់ៗឱ្យបាន៥នាក់។ ២-ចូរពណ៌នាពីចលនាតស៊ូដើម្បីទទួលបានឯករាជ្យ។ ៣-ចូរពណ៌នារបបសាធារណរដ្ឋប្រជាមានិតខ្មែរ។ ៤-ហេតុអ្វីបានជាកើតមានរដ្ឋប្រហារឆ្នាំ១៩៧០? តើរដ្ឋប្រហារនេះផ្តល់ផលវិបាកដូចម្តេចខ្លះ?
☒ ២០២០ មិនមានការប្រឡងនោះទេ ☒	
សម័យប្រឡង ២៧ ធ្នូ ២០២១	
១-តើអ្វីជាសមាគមប្រទេសអាស៊ាន?	១-តើសមាគមអាស៊ាន មានប្រទេសណាខ្លះជាសមាជិក?

២-តើអាណាព្យាបាលបារាំងបាននាំមកនូវអ្វីខ្លះ ដល់ប្រទេសកម្ពុជា? ៣-ពិពណ៌នាពីមូលហេតុនៃរដ្ឋប្រហារឆ្នាំ១៩៧០ទម្លាក់សម្តេចព្រះសីហនុពីតំណែង។ ៤-តើហេតុអ្វីបានជារបប "កម្ពុជាប្រជាធិបតេយ្យដួលរលំ"? ៥-ចូរអ្នកពិពណ៌នាពីគោលនយោបាយបង្រួបបង្រួមជាតិដើម្បីស្វែងរកសន្តិភាពនៅកម្ពុជា។	២-ចូរអ្នកពិពណ៌នាពីបញ្ហាធំៗនៅក្នុងពិភពលោក? ៣-ចូរអ្នកពិពណ៌នាពីសមិទ្ធផលសំខាន់ៗរបស់រដ្ឋាភិបាលកម្ពុជា? ៤-ចូរអ្នកវិភាគពីតួនាទីនៃសន្តិភាពក្នុងការអភិវឌ្ឍប្រទេសកម្ពុជា?
សម័យប្រឡង ០៥ ធ្នូ ២០២២	
១-តើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ កើតឡើងនៅឆ្នាំណា និងបាននាំមកអ្វីខ្លះសម្រាប់កម្ពុជា? ២-មូលហេតុបានជាគេចាត់ទុកថា សម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ជាបិតាសន្តិភាពនៅកម្ពុជា? ៣-តើសង្គ្រាមត្រជាក់ជាអ្វី? វាមានផលវិបាកអ្វីខ្លះដល់ពិភពលោក? ៤-ថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ មានអត្ថន័យជាប្រវត្តិសាស្ត្រអ្វីខ្លះ សម្រាប់កម្ពុជា? ៥-តើអ្វីទៅជាគោលនយោបាយឈ្នះ ឈ្នះ?	១-តើសមាគមអាស៊ានមានសមាជិកចំនួនប៉ុន្មានប្រទេស? តើការចូលជាសមាជិកអាស៊ានផ្តល់ផលប្រយោជន៍អ្វីសម្រាប់កម្ពុជា? ២-តើអាណានិគមនិយមបារាំងបាននាំអ្វីខ្លះដល់កម្ពុជា? ៣-ចូររាប់ពីបញ្ហាសន្តិសុខស្បៀងលើពិភពលោក។ ៤-ចូររាប់ពីមូលហេតុនិងផលវិបាកនៃសាកលភាវូបនីយកម្ម។ ៥-តើថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ មានអត្ថន័យជាប្រវត្តិសាស្ត្រអ្វីខ្លះ សម្រាប់កម្ពុជា?
សម័យប្រឡង ០៦ វិច្ឆិកា ២០២៣	
១-តើកម្ពុជាមានបេតិកភណ្ឌអ្វីខ្លះ ដែលបានចុះបញ្ជីបេតិកភណ្ឌរូបី និងអរូបី	១-តើកម្ពុជាមានបេតិកភណ្ឌអ្វីខ្លះ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌរូបី និង

ពិភពលោករបស់អង្គការយូណេស្កូ? ចូររៀបរាប់ឱ្យបាន៥។ ២-ចូរអ្នកវិភាគពីមូលហេតុអាណានិគមបារាំងនៅកម្ពុជា និងការតស៊ូដើម្បីឯករាជ្យជាតិ។ ៣-ចូរអ្នកពណ៌នាពីនយោបាយអព្យាក្រឹតនៃរបបសង្គមរាស្ត្រនិយម ក្នុងទសវត្សរ៍១៩៦០។ ៤-តើពិភពលោកមានបញ្ហាប្រឈមធំៗអ្វីខ្លះ? ចូរអ្នកពណ៌នា។ ៥-ចូរអ្នកពណ៌នាពីការរំដោះប្រទេសកម្ពុជាពីរបបកម្ពុជាប្រជាធិបតេយ្យ និងដំណើរការស្ថាបនាជាតិឡើងវិញ។	អរូបីពិភពលោករបស់អង្គការយូណេស្កូ? ចូរអ្នករៀបរាប់ឱ្យបាន៥។ ២-ចូរអ្នកវិភាគពីមូលហេតុនៃការបង្កើតរបបសង្គមរាស្ត្រនិយម(១៩៥៥-១៩៧០) ។ ៣-ចូរអ្នកវិភាគពីមូលហេតុនៃការបង្កើតសាធារណរដ្ឋខ្មែរនៅឆ្នាំ១៩៧០ និងផលលំបាកនៃសង្គ្រាម។ ៤-ចូរអ្នកពិពណ៌នាពីកត្តាសំខាន់ៗដែលនាំឱ្យមានជ័យជម្នះលើរបបប្រល័យពូជសាសន៍នៅថ្ងៃទី៧ មករា ១៩៧៩។ ៥-តើអ្វីទៅជា«នយោបាយបង្រួបបង្រួមជាតិ» នៅចុងទសវត្សឆ្នាំ១៩៨០? ចូរអ្នកពិពណ៌នាពីដំណើរចរចារកសន្តិភាពដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា។
សម័យប្រឡង ០៨ តុលា ២០២៤	
១-កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន និងជាមួយប្រទេសជិតខាងនាំមកនូវផលប្រយោជន៍អ្វីខ្លះ ដល់កម្ពុជា? ២-ចូរពណ៌នាពីបញ្ហាប្រឈមធំៗដែលពិភពលោកកំពុងជួបប្រទះ។ ៣-ចូរវិភាគពីមូលហេតុ និងផលវិបាកនៃសង្គ្រាមឆ្នាំ១៩៧០-១៩៧៥ នៅក្នុងរបបសាធារណរដ្ឋខ្មែរ។ ៤-តើរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)បាន	១-កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌអាស៊ាន និងជាមួយប្រទេសជិតខាងនាំមកនូវផលប្រយោជន៍អ្វីខ្លះ ដល់កម្ពុជា? ២-តើអ្វីជាសង្គ្រាមត្រជាក់? តើសង្គ្រាមត្រជាក់មានផលវិបាកអ្វីខ្លះ ដល់កម្ពុជា? ៣-ចូរអ្នកវិភាគពីមូលហេតុដែលរបបសង្គមរាស្ត្រនិយម(១៩៥៥-១៩៩៧០) នូវរបបនយោបាយអព្យាក្រឹតនៅកម្ពុជា?

នាំមកនូវសោកនាដកម្មអ្វីខ្លះ ដល់កម្ពុជា? ៥-ចូរអ្នកវិភាគពីសមិទ្ធផលខាងផ្នែកសេដ្ឋកិច្ច និងសង្គមដែលកម្ពុជាទទួលបាន ក្នុងការអភិវឌ្ឍប្រកបដោយសន្តិភាព។	៤-តើអ្វីជានយោបាយបង្រួបបង្រួមជាតិដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា? ៥-តើសុខសន្តិភាពបាននាំអ្វីខ្លះ ដល់កម្ពុជាក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ?
សម័យប្រឡង ២៨ សីហា ២០២៥	
១-ចូររាប់ឈ្មោះប្រាសាទបុរាណខ្មែរឱ្យបាន៥។ ២-ចូរពណ៌នាពីមូលហេតុដែលកម្ពុជាទទួលយកអាណានិគមនិយមបារាំង និងចលនាទាមទារឯករាជ្យពីបារាំង។ ៣-ចូរវិភាគពីទំនាក់ទំនងរវាងសង្គ្រាមត្រជាក់ និងសង្គ្រាមក្នុងរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥)។ ៤-ចូរវិភាគពីសមិទ្ធផលសំខាន់ៗនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមក្នុងប្រទេសកម្ពុជាជាង៣ទសវត្សកន្លងមក និងកត្តានាំឱ្យកម្ពុជាចាកចេញពីក្រុមប្រទេសអភិវឌ្ឍតិចតួច។ ៥-ចូរពណ៌នាពីអត្ថន័យប្រវត្តិសាស្ត្រនៃការដាក់ប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។	១-ចូររាប់ឈ្មោះប្រាសាទបុរាណឱ្យបាន៥។ ២-បញ្ហាសន្តិសុខស្បៀងនៅលើពិភពលោក។ តើកត្តាអ្វីខ្លះដែលនាំអោយកម្ពុជាដោះស្រាយបញ្ហាសន្តិសុខស្បៀងបាន? ៣-តើការដាក់ប្រាសាទព្រះវិហារចូលសម្បត្តិបេតិកភណ្ឌពិភពលោកមានអត្ថន័យជាប្រវត្តិសាស្ត្រអ្វីខ្លះ? ៤-មូលហេតុអ្វីបានជាយុវជនត្រូវយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរ និងប្រវត្តិសាស្ត្រពិភពលោក? ៥-តើក្នុងរជ្ជកាលមហាក្សត្រអង្គណាដែលទទួលអាណាព្យាបាលបារាំង? ផ្តល់ផលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះ?
សម័យប្រឡង ១០ សីហា ២០២៦	
១-តើអាណាចក្រខ្មែរចាប់ផ្តើមនៅពេលណា? ហេតុអ្វីបានជាអាណាចក្រខ្មែរធ្លាក់ចុះ?	១-តើអ្វីទៅជាសកលភាវូបនីយកម្ម? ២-ចូរពណ៌នាពីនយោបាយការបរទេសអព្យាក្រឹតនៃរបបសង្គមរាស្ត្រនិយមក្នុង

២-ចូរពណ៌នាពីអាណានិគមនិយមបារាំងនៅកម្ពុជា។ ៣-ចូរពណ៌នាពីមូលហេតុនៃការធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្ត សីហនុ និងផលវិបាកនៅឆ្នាំ១៩៧០ មានផលវិបាកទៅលើកម្ពុជាដូចម្តេច? ៤-ចូរពណ៌នាពីការកសាងជាតិពីចំណុចសូន្យក្នុងទសវត្សឆ្នាំ១៩៩៨។ ៥-ចូរពណ៌នាពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗនៅវត្សឆ្នាំ១៩៥០ ដល់បច្ចុប្បន្ន។	បរិបទសង្គ្រាមត្រជាក់។ ៣-ចូរពណ៌នាពីបញ្ហាធំៗលើសកលលោក។ ហេតុអ្វីបានជាបញ្ហានេះជាបញ្ហាប្រឈម។ ៤-ចូរពណ៌នាពីនយោបាយឈ្នះ ឈ្នះ តួអង្គសំខាន់ និងអត្ថន័យជាប្រវត្តិសាស្ត្រសម្រាប់កម្ពុជា? ៥-ចូរពណ៌នាពីការអភិវឌ្ឍសេដ្ឋកិច្ចក្រោយបញ្ចប់សង្គ្រាមក្នុងទសវត្សរ៍ឆ្នាំ១៩៩០។

ចម្លើយនៃវិញ្ញាសាធ្លាប់ចេញកន្លងមកនេះ ប្អូនៗ*អាចស្វែងរក*នាតាមមេរៀននីមួយៗ និងនៅក្នុងផ្នែកសំណួរចម្លើយជ្រើសរើសពិសេសបាន។

ខ្ញុំមិនរៀបចំអត្រាកំណែតាមវិញ្ញាសានីមួយៗ ព្រោះមានសំណួរជាន់ៗគ្នាជាដែលៗច្រើន និងដើម្បីកាត់បន្ថយកម្រាស់នៃទំព័រសៀវភៅកុំឱ្យច្រើនពេក។

សំណួរគន្លឹះចាំង១០ សម្រាប់ហ្វឹកហាត់

សំណួរគន្លឹះ



១-ចូរពណ៌នាពីរបបសង្គមអាស្រ្តនិយម(១៩៥៥-១៩៧០)។

២-ចូរពណ៌នាពីរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥)។

៣-ចូរពណ៌នាពីរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។

៤-ចូរពណ៌នាពីសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)។

៥-ចូរពណ៌នាពីព្រះរាជាណាចក្រកម្ពុជាទី២(១៩៩៣-បច្ចុប្បន្ន)។

៦-ចូររៀបរាប់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងរបបសង្គមអាស្រ្តនិយម។

៧-ចូររៀបរាប់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងរបបសាធារណរដ្ឋខ្មែរ។

៨-ចូររៀបរាប់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

៩-ចូររៀបរាប់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា។

១០-ចូររៀបរាប់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗនៅសម័យសង្គមអាស្រ្តនិយម។

សូមប្អូនៗថ្នាក់ទី១២ ហ្វឹកហាត់ធ្វើសំណួរគន្លឹះទាំង១០នេះឱ្យបានស្ទាត់


ដើម្បីមានមូលដ្ឋានក្នុងការឆ្លើយសំណួរ/ប្រឡងនានា

ជូនពរប្អូនៗទទួលបានជោគជ័យក្នុងការសិក្សាតាមបំណងប្រាថ្នា!

ប្រវត្តិវិទ្យា

ថ្នាក់ទី១២

- សំណួរ-ចម្លើយលម្អិតកម្រិតខ្ពស់
- ត្រៀមប្រឡងបាក់ឌុបឆ្នាំ២០២៧
- ពង្រីកចំណេះដឹងបន្ថែម
- ស្របតាមកម្មវិធីសិក្សាថ្មីឆ្នាំ២០២៦



✧សៀវភៅនេះសម្រាប់:

- ជាមគ្គុទេសក៍សម្រាប់មន្ត្រីនិងសិស្ស
- ត្រៀមប្រឡងឆមាស១-២
- ត្រៀមប្រឡងប្រជែងនានា
- ពង្រីកចំណេះដឹងបន្ថែម

តម្លៃ **7$**

ចេញលក់ហើយ!

ងាយយល់ | ស.ច.ម.ល | ចំគោលដៅ

លិន ចណ្ឌី

ទំនាក់ទំនងតាមរយៈ





